**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ក្រុមប្រឹក្សាជាតិគណនេយ្យ**

លេខ ២៧៣ សហវ.គជគ

រាជធានីភ្នំពេញ, ថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១

ត្រូវនឹងថ្ងៃទី ២៧ ខែ វិច្ឆិកា គ.ស. ២០១៧

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអញ្ជើញចូលរួមពិគ្រោះថ្លៃការផ្គត់ផ្គង់សម្ភារបច្ចេកទេស

ក្រុមប្រឹក្សាជាតិគណនេយ្យ សូមជម្រាបជូនដំណឹងដល់បណ្ដាក្រុមហ៊ុន សហគ្រាស ( គិតទាំងសហគ្រាសឯកត្តបុគ្គល ) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា : ក្រុមប្រឹក្សាជាតិគណនេយ្យនឹងដាក់ឲ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារបច្ចេកទេស ។

ក្រុមប្រឹក្សាជាតិគណនេយ្យ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញបែបបទ ដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់ឯកសារពិគ្រោះថ្លៃនៅក្រុមប្រឹក្សាជាតិគណនេយ្យ ដែលមានអាសយដ្ឋានផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០១៧ រៀងរាល់ម៉ោងធ្វើការ ។

កាលបរិច្ឆេទឈប់ទទួលសំណើពិគ្រោះថ្លៃ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ៣:៣០ នាទីរសៀល ។

ការបើកឯកសារពិគ្រោះថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមប្រឹក្សាជាតិគណនេយ្យ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ៣:៣០ នាទីរសៀល ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬប្រភពតែមួយអាចដាក់ឯកសារពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន / សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ តាមទូរស័ព្ទលេខ 023 432 154 ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ ។

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**និងជាប្រធានក្រុមលទ្ធកម្ម**

**ឌី_តាយី**

**ចម្លងជូន :**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៩៩១ ០៣៦ , ទូរសារ : ៨៥៥-២៣ ៩៩០ ៦៦៣

Phone: 855-23-991 036 , Fax: 855-23-990 663